# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមិថុនា ឆ្នាំ២០១៧

*នៅក្នុងខែមិថុនា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក*

*-អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល គម្រប់ព្រះជន្មាយុ៨១ យាងចូល៨២ ព្រះវស្សា នៅព្រះរាជដំណាក់គន្ធបុប្ផា ព្រះបរមរាជវាំង*

*-អនុញ្ញាតឲ្យឯកឧត្តម* **Amdrès Parstrana Arango** *ប្រធាន* CDI-International *និងជាអតីតប្រធានាធិបតីកូឡុំប៊ី និងក្រុមអ្នកអង្កេតការណ៍បោះឆ្នោតអន្តរជាតិចំនួន២៩រូប ដែលមកពីក្រុមសន្និសីទអន្តរជាតិ ចូលជួបសម្តែងការគួរសម និងសវនាការ*

*-អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍អបអរសាទរខួបលើកទី៥នៃទំនាក់ទំនងការទូតកម្ពុជា វៀតណាម នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា*

*-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់២ឆ្នាំ និងគម្រប់៨ឆ្នាំ ដើម្បីឧទ្ទិសមហាកុសលជូនចំពោះវិញ្ញាណក្ខន្ធ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន** នៅភូមិកន្ទែងជ្រៅ ឃុំក្រពៅ ស្រុកកំចាយមា ខេត្តព្រៃវែង*

*-អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់១០០ថ្ងៃ សម្តេចវិបុលបញ្ញា **សុខ អាន** នៅរាជធានីភ្នំពេញ*

*-អញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **សឿ ភូ** ជាភរិយារបស់ឯកឧត្តម **ជុំ វង់** សមាជិកគណៈកម្មការទី៦ ព្រឹទ្ធសភា នៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧៨ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់២ឆ្នាំ និងគម្រប់៨ឆ្នាំ ដើម្បីឧទ្ទិសមហាកុសលជូនចំពោះវិញ្ញាណក្ខន្ធ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន** នៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញដឹកនាំប្រជុំត្រៀមចូលរួមកិច្ចប្រជុំប្រធានសភាលើកទី២ នៅប្រទេសអាស៊ី-អឺរ៉ុប

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមក្នុងកិច្ចប្រជុំប្រធានសភាលើកទី២ ប្រទេសអាស៊ី-អឺរ៉ុប នៅសាធារណរដ្ឋកូរ៉េ

-អញ្ជើញចូលរួមប្រជុំការងារគណៈកម្មាធិការប្រតិបត្តិ ដើម្បីប្រកាសទទួលស្គាល់អនុប្រធានសមាគមមិត្តភាពកម្ពុជា-ចិន និងបញ្ហាផ្សេងៗមួយចំនួនទៀត

-អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត ក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅខេត្តកណ្តាល ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភដល់សិល្បករ សិល្បការិនីចំនួន៣០០នាក់ នៅមជ្ឈមណ្ឌលកោះពេជ្រ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧៧ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក**:

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

### ៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :

*ក្នុងខែមិថុនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:*

#### ៣.១.មុខងារនីតិកម្ម

*-អញ្ជើញចូលរួមប្រជុំជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ដើម្បីពិនិត្យលើសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា*

*-អញ្ជើញចូលរួមក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៥ នៃរដ្ឋសភា ដើម្បីឆ្លើយបំភ្លឺលើសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។*

#### ៣.២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

*-អញ្ជើញចុះសិក្សាឈ្វេងយល់ពីកត្តាសំខាន់ៗ ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅជុំវិញបឹងទន្លេសាប ។*

#### ៣.៣.មុខងារតំណាង

*-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០២ករណី និងកំពុងពិនិត្យសិក្សាចំនួន០២ករណី ព្រមទាំងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី*

*-អញ្ជើញចូលរួមសិក្ខាសាលា និងកិច្ចពិភាក្សាអំពីទស្សនទាននៃផលប្រយោជន៍ និងការរៀបចំក្រុមប្រតិបត្តិសម្រាប់មន្ត្រីសាធារណៈ*

*-អញ្ជើញចូលរួមប្រជុំការងារ ដែលត្រូវអញ្ជើញចូលរួមមហាសន្និបាតសភានិយាយភាសាបារាំង* (APF) *លើកទី៤៣ នៅប្រទេសលុចសំបួរ*

*-អញ្ជើញចូលរួមប្រជុំ ដើម្បីរៀបចំខ្លឹមសារត្រៀមបំពេញទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាបារាំង*

*-អញ្ជើញជួបពិភាក្សាការងារជាមួយលោក* ***ហាខាន់ អាតាសេវ៉ែ*** **(Mr. Hakan Atasever)** *នាយកប្រតិបត្តិនៃវិទ្យាស្ថានសន្ទនាមេគង្គ*(MDI) *និងសហការី ដើម្បីពិភាក្សា*

អំពីគម្រោងអញ្ជើញសមាជិកព្រឹទ្ធសភា ចូលរួមពិធីពិសាអាហារមិត្តភាពក្នុងពិធីស្រាយបួសខែរ៉ាម៉ាឌន (Ramadan) នៃសាសនាឥស្លាមកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងបឋកថាស្តីពី តួនាទីជាយុទ្ធសាស្ត្ររបស់កម្ពុជាក្នុងការទទួលខុសត្រូវដើម្បីបង្ការ និងរិជានការទប់ស្កាត់អំពើឃោរឃៅ នៅវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

-អញ្ជើញចូលរួមប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីស្នើសុំសាស្ត្រាចារ្យជំនាញកសិកម្ម ផ្នែកដាំដុះ ចុះជួយប្រជាកសិករ ស្រុកសំឡូត ពីបច្ចេកទេសពែទាំដាំដុះ

-អញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូឯកជនមកពីប្រទេសជប៉ុន ស្តីពីសក្តានុពលវិនិយោគនៅស្រុកសំឡូត ខេត្តបាត់ដំបង ។

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន៣៣៩លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៦លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទៅទស្សនកិច្ចសិក្សាឈ្វេងយល់នូវបច្ចេកវិទ្យាទំនើបៗ និងចំណេះដឹងទាក់ទងនឹងវិស័យចិញ្ចឹមសត្វ ការកែច្នៃចំណីអាហារ ការធ្វើទំនើបកម្មកសិដ្ឋាន និងការអភិវឌ្ឍជនបទ នៅប្រទេសហុងគ្រី និងប្រទេសបារាំង

-ឯកឧត្តម **ប៊ូ ថង** អញ្ជើញជួបសំណេះសំណាល និងផ្លាស់ប្តូរព័ត៌មានថ្មីៗ(កម្ពុជា-ឡាវ) ជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតឡាវប្រចាំនៅកម្ពុជា

-ឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញទៅទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរីប្រចាំនៅទីក្រុងភ្នំពេញ ដើម្បីត្រៀមរៀបចំដំណើរទស្សនកិច្ចសិក្សា

-អនុញ្ញាតឲ្យគណៈប្រតិភូមកពីប្រទេសប៉ូឡូញ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ដើម្បីរកដំណោះស្រាយអំពីតម្លៃសាច់ជ្រូក និងសាច់មាន់ឲ្យមានទីផ្សារឡើងវិញ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ